KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR. 42/2025 MFA.IC

PRESS RELEASE

# Cambodia and Morocco Agree on Roadmap to Strengthen Multi-sectoral Partnership and Future Collaboration

**His Excellency Deputy Prime Minister PRAK Sokhonn**, Minister of Foreign Affairs and International Cooperation of the Kingdom of Cambodia, held a virtual meeting with **His Excellency Nasser BOURITA**, Minister of Foreign Affairs, African Cooperation and Moroccan Expatriates of the Kingdom of Morocco, to enhance the long-standing friendship and cooperation between the two Kingdoms.

The two Ministers noted with satisfaction the progress of Cambodia-Morocco bilateral relations and discussed ways to deepen cooperation in trade, investment, tourism, science and technology, and sub-national partnerships, including sister-city initiatives. They welcomed the positive momentum in bilateral cooperation and looked forward to the early conclusion of remaining draft agreements in these areas. Both Ministers also encouraged regular engagements between sectoral ministries of both countries—particularly in agriculture, tourism, energy, and transport—through reciprocal visits and virtual exchanges to strengthen mutually beneficial cooperation.

His Excellency PRAK Sokhonn highlighted that 2026 will mark the 30th anniversary of the establishment of diplomatic relations between the Kingdom of Cambodia and the Kingdom of Morocco, a significant milestone that reflects three decades of enduring friendship, mutual respect, and fruitful cooperation. He expressed confidence that this important occasion will serve as a new impetus to further strengthen and expand bilateral relations in areas of common interest. In this regard, the two Ministers agreed to organize meaningful commemorative activities next year, including cultural weeks in each other's capitals.

Both sides reaffirmed their commitment to mutual support in regional and international fora, with His Excellency Nasser BOURITA reiterating Morocco's support for Cambodia's candidature as a

Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

member of the Economic and Social Council ( ECOSOC ) for 2028-2030, and as a member of the Inter-governmental Committee for the Safeguarding of Intangible Cultural Heritage ( ICS-ICH ) for 2026-2030.

In a gesture of strong support for Cambodia's hosting of next year's Francophonie Summit, His Excellency BOURITA announced Morocco's decision to increase the annual scholarship quota from 20 to 30 for Cambodian students pursuing studies in Morocco, particularly in diplomacy and international relations in French. He further affirmed that Morocco will be represented at the Summit at the highest level, underscoring the close and enduring ties between the two countries.

The Ministers also exchanged views on regional and international issues, underscoring that peace, justice, and mutual respect remain essential foundations for global stability and prosperity. His Excellency PRAK Sokhonn briefed his counterpart on the developments in finding the peaceful settlement of the border conflict between Cambodia and Thailand.

Following the meeting, both Ministers signed a **Joint Communiqué**, which serves as a roadmap to advance multi-sectoral cooperation in celebration of the 30th anniversary of diplomatic relations between Cambodia and Morocco in 2026.

Phnom Penh, 21 October 2025

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ៤២/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## កម្ពុជា និងម៉ារ៉ុក បានឯកភាពគ្នាលើផែនទីបង្ហាញផ្លូវ ដើម្បីពង្រឹងភាពជាដៃគូពហុវិស័យ និងកិច្ចសហប្រតិបត្តិការនាពេលអនាគត

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** នៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាការងារតាមប្រព័ន្ធវីដេអូជាមួយ **ឯកឧត្តម** Nasser BOURITA រដ្ឋមន្ត្រីក្រសួងការបរទេស សហប្រតិបត្តិការអាហ្វ្រិក និងជនអន្តោប្រវេសន៍ម៉ារ៉ុក នៃព្រះរាជាណាចក្រម៉ារ៉ុក ដើម្បីបង្កើនទំនាក់ទំនងកិច្ចសហ-ប្រតិបត្តិការ និងមិត្តភាពរវាងព្រះរាជាណាចក្រទាំងពីរ។

រដ្ឋមន្ត្រីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តចំពោះវឌ្ឍនភាពនៃទំនាក់ទំនងទ្វេភាគីកម្ពុជា-ម៉ារ៉ុក នាពេលកន្លងមក ហើយបានពិភាក្សាអំពីវិធីសាស្ត្រធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងភាពជាដៃគូថ្នាក់ស្ថាប័ននៅថ្នាក់ក្រោមជាតិ ដែលរួមមានការចងសម្ព័ន្ធមេត្រីភាពរវាងទីក្រុងនានានៃប្រទេសទាំងពីរ។ សមភាគីទាំងពីរបានស្វាគមន៍ចំពោះសន្ទុះវិជ្ជមាននៃកិច្ចសហប្រតិបត្តិការទ្វេភាគី ហើយទន្ទឹងរង់ចាំការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗក្នុងវិស័យទាំងនេះនៅពេលខាងមុខ។ រដ្ឋមន្ត្រីទាំងពីរក៏បានលើកទឹកចិត្តឱ្យមានការទាក់ទងគ្នាជាទៀតទាត់រវាងក្រសួង-ស្ថាប័ននៃប្រទេសទាំងពីរ ជាពិសេសក្នុងវិស័យកសិកម្ម ទេសចរណ៍ ថាមពល និងការដឹកជញ្ជូន ទាំងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមក ទាំងការជួបពិភាក្សាតាមប្រព័ន្ធវីដេអូ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។

**ឯកឧត្តម ប្រាក់ សុខុន** បានគូសបញ្ជាក់ថា នៅឆ្នាំ២០២៦ គឺជាខួបលើកទី៣០ នៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រម៉ារ៉ុក ដែលជាព្រឹត្តិការណ៍ដ៏សំខាន់ដែលឆ្លុះបញ្ចាំងពីរយៈពេលបីទសវត្សរ៍នៃទំនាក់ទំនងមិត្តភាព ការគោរពគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបង្ហាញទំនុកចិត្តថា ឱកាសដ៏មានសារៈសំខាន់នេះនឹងដើរតួជាកម្លាំងចលករថ្មីមួយក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងទ្វេភាគីលើវិស័យដែលមានផលប្រយោជន៍រួម។ ក្នុងន័យនេះ រដ្ឋមន្ត្រីទាំងពីរបានឯកភាពគ្នារៀបចំសកម្មភាពផ្សេងៗ ដើម្បីរំលឹកខួបនៃទំនាក់ទំនងការទូតដ៏មានអត្ថន័យនៅឆ្នាំក្រោយ រួមមានការរៀបចំកម្មវិធីសប្តាហ៍វប្បធម៌នៅក្នុងរាជធានីនៃប្រទេសទាំងពីរ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ភាគីទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តចំពោះការគាំទ្រទៅវិញទៅមកក្នុងវេទិកាតំបន់ និងអន្តរជាតិ ដោយឯកឧត្តម Nasser BOURITA បានបញ្ជាក់សារជាថ្មីនូវការគាំទ្ររបស់ម៉ារ៉ុកសម្រាប់បេក្ខភាពរបស់កម្ពុជាជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC) សម្រាប់អាណត្តិ ២០២៨-២០៣០ និងបេក្ខភាពរបស់កម្ពុជា ជាសមាជិកនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌អរូបី (ICS-ICH) សម្រាប់ឆ្នាំ២០២៦-២០៣០។

ក្នុងស្មារតីគាំទ្រសម្រាប់ប្រទេសកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី នៅឆ្នាំក្រោយ ឯកឧត្តម BOURITA បានប្រកាសថាប្រទេសម៉ារ៉ុកនឹងបង្កើនចំនួនអាហារូបករណ៍ប្រចាំឆ្នាំពី២០កន្លែង ទៅ ៣០កន្លែង សម្រាប់និស្សិតកម្ពុជាដែលបន្តការសិក្សានៅប្រទេសម៉ារ៉ុក ជាពិសេសផ្នែកការទូត និងទំនាក់ទំនងអន្តរជាតិ ជាភាសាបារាំង។ លោកបានបញ្ជាក់បន្ថែមថា ថ្នាក់ដឹកនាំជាន់ខ្ពស់ម៉ារ៉ុកនឹងចូលរួមក្នុងកិច្ចប្រជុំកំពូលខាងលើ ដើម្បីបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងយូរអង្វែងរបស់ប្រទេសទាំងពីរ។

រដ្ឋមន្ត្រីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាតំបន់ និងអន្តរជាតិ ដោយគូសបញ្ជាក់ថាសន្តិភាព យុត្តិធម៌ និងការគោរពគ្នាទៅវិញទៅមក នៅតែជាមូលដ្ឋានគ្រឹះដ៏សំខាន់មិនអាចខ្វះបានសម្រាប់ស្ថិរភាព និងវិបុលភាពពិភព-លោក។ ឯកឧត្តម ប្រាក់ សុខុន បានជម្រាបជូនសមភាគីម៉ារ៉ុក អំពីការវិវត្តន៍ក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះព្រំដែនកម្ពុជា-ថៃ។

បន្ទាប់ពីជំនួបនោះ រដ្ឋមន្ត្រីទាំងពីរបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួម ដែលជាផែនទីបង្ហាញផ្លូវឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការពហុវិស័យ ដើម្បីអបអរសាទរខួបលើកទី៣០ នៃទំនាក់ទំនងការទូតរវាងកម្ពុជា និងម៉ារ៉ុក នៅឆ្នាំ២០២៦ ខាងមុខ។

ថ្ងៃអង្គារ ១៤រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥